ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២០៣ ប្រក កសក

# ប្រកាស

# ស្តីពី

# បែបបទ និង នីតិវិធីសម្រាប់ការស្នើសុំ និង ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ. បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ
- បានឃើញប្រកាសលេខ ០៨៦ប្រក.កសក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៤ ស្តីពីការដាក់ឱ្យប្រើបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- តាមសំណើរបស់នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ⁄

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់នូវបែបបទ និង នីតិវិធីសម្រាប់ការស្នើសុំ និង ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ក្នុងគោលបំណងធានាបាននូវលក្ខខណ្ឌសមស្របក្នុងការស្នើសុំសម្រាប់អ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូ សំដៅផ្តល់នូវជំនឿទុកចិត្តដល់ទីផ្សារជាតិ និង អន្តរជាតិក្នុងការធ្វើពាណិជ្ជកម្មកៅស៊ូដែលមានប្រភពដើមផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូ ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា ត្រូវធ្វើលិខិតស្នើសុំធ្វើតេស្តមកមន្ទីរពិសោធន៍វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ដោយភ្ជាប់ជាមួយភាគសំណាកដែលមានស្លាកសម្គាល់ច្បាស់លាស់ ។ វិធីសាស្ត្រនៃការយកសំណាកកៅស៊ូដើម្បីធ្វើតេស្តគុណភាព ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ភ្ជាប់ប្រកាសនេះ ។

ភាគសំណាកដែលបានទទួលនៅមន្ទីរពិសោធន៍ត្រូវបានត្រួតពិនិត្យត្រឹមត្រូវ និង ត្រូវចុះក្នុងបញ្ជីទទួលភាគសំណាក រួចបិទស្លាកមន្ទីរពិសោធន៍។ អ្នកទទួលត្រូវបំពេញប័ណ្ណទទួលសំណាកចំនួន ០២ (ពីរ) ច្បាប់ និង ចុះហត្ថលេខាដោយភាគីទាំងពីរ។ ប័ណ្ណ ០១ (មួយ) ច្បាប់ផ្តល់ឱ្យអ្នកបញ្ជូនភាគសំណាក និង ០១ (មួយ) ច្បាប់ទៀតរក្សាទុកក្នុងមន្ទីរពិសោធន៍ ។

ការធ្វើតេស្តភាគសំណាកត្រូវធ្វើឡើងស្របតាមវិធីសាស្ត្រវិភាគដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ។

**ប្រការ ៣ :** រាល់របាយការណ៍តេស្តដែលចេញឱ្យអ្នកកែច្នៃកៅស៊ូ ឬ អ្នកនាំចេញកៅស៊ូត្រូវចុះក្នុងបញ្ជីរបាយការណ៍តេស្ត ។ ក្រោយពីទទួលរបាយការណ៍តេស្ត វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាដែលបានធ្វើតេស្តនោះជូនអ្នកស្នើសុំ។ គំរូរបាយការណ៍តេស្តចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង របាយការណ៍តេស្តចេញដោយមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ និងទី៣ ភ្ជាប់ប្រកាសនេះ។

អ្នកស្នើសុំមានកាតព្វកិច្ចបង់កម្រៃសេវាកម្មជូនវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ការធ្វើតេស្ត និង ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា។

**ប្រការ ៤ :** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្រចំនួន ០៥ (ប្រាំ) ច្បាប់ដើម ដោយត្រូវ :

-ប្រគល់ឱ្យអ្នកស្នើសុំចំនួន ០២ (ពីរ) ច្បាប់

-រក្សាទុកនៅមន្ទីរពិសោធន៍ចំនួន ០១ (មួយ) ច្បាប់

-រក្សាទុកនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន ០១ ( មួយ) ច្បាប់

-ប្រគល់ឱ្យភ្នាក់ងារមានសមត្ថកិច្ច ០១ ( មួយ) ច្បាប់ ជាឯកសារភ្ជាប់សម្រាប់នាំចេញ ។

វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា អាចផ្តល់ឱ្យតែរោងចក្រកែច្នៃកៅស៊ូណា ដែលបានចុះបញ្ជិកា នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាប៉ុណ្ណោះ ។

**ប្រការ ៥ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** អគ្គនាយកនៃក្រសួង អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានចំការកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និង ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៨

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ